ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...១០៨.......អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមករា ឆ្នាំ ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពីការប្រឡងភ្នាក់ងារសេវាកម្មពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនលោក លោកស្រី ដែលជាអ្នកជាប់ពន្ធ សិស្ស និស្សិត បុគ្គលិកក្រុមហ៊ុន និងសាធារណជនទូទៅ ដែលបានដាក់ពាក្យប្រឡងភ្នាក់ងារសេវាកម្មពន្ធដារ នៅសាលាជាតិពន្ធដារ មេត្តាជ្រាបថា ការប្រឡងជ្រើសរើសភ្នាក់ងារសេវាកម្មពន្ធដារ នឹងប្រព្រឹត្តទៅនៅថ្ងៃទី **១០ ខែមករា ឆ្នាំ២០១៥**។ ក្នុងគោលបំណងដើម្បីឱ្យដំណើរការប្រឡងប្រព្រឹត្តទៅបានល្អប្រសើរ អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំដូចខាងក្រោម ÷

១. បេក្ខជនទាំងអស់ត្រូវមកពិនិត្យឈ្មោះ លេខតុ លេខបន្ទប់ និងព័ត៌មានផ្ទាល់ខ្លួន នៅថ្ងៃ ទី០៨ ខែមករា ឆ្នាំ២០១៥

២. បេក្ខជនទាំងអស់ត្រូវមានវត្តមាននៅសាលាជាតិពន្ធដារ នៅវេលាម៉ោង ៧:០០ (ព្រឹក) នាថ្ងៃប្រឡង ដើម្បីស្កែនម្រាមដៃ និងផ្ទៀងផ្ទាត់សលាកបត្រ

៣. បេក្ខជនត្រូវមានម៉ាស៊ីនគិតលេខផ្ទាល់ខ្លួន (ហាមប្រើប្រាស់ម៉ាស៊ីនគិតលេខដែលអាចផ្ទុកឯកសារបាន)

៤. បេក្ខជនមិនត្រូវយកមកជាមួយនូវ ទូរស័ព្ទ វិទ្យុទាក់ទង ឧបករណ៍អេឡិចត្រូនិច ដែលអាចផ្ទុកឯកសារចូលក្នុងបន្ទប់ប្រឡង

៥. រាល់សម្ភារផ្សេងៗរបស់បេក្ខជន មិនអនុញ្ញាតឱ្យយកចូលក្នុងបរិវេណនៃមណ្ឌលប្រឡងឡើយ អគ្គនាយកដ្ឋានពន្ធដារមិនទទួលខុសត្រូវរាល់ការបាត់បង់សម្ភារទាំងឡាយរបស់បេក្ខជនទេ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកសាលាជាតិពន្ធដារ ដែលមានអាសយដ្ឋានអគារលេខ ៤១-៤៣ ផ្លូវលេខ ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ខាងកើតអគ្គនាយកដ្ឋានពន្ធដារ)

**អគ្គនាយកដ្ឋានពន្ធដារ**

ព្រះរាជាណាចក្រកម្ពុជា
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៤៤១១ អពដ

GENERAL DEPARTMENT OF TAXATION

**កម្មវិធីប្រឡងជ្រើសរើសភ្នាក់ងារសេវាកម្មពន្ធដារលើកទីពីរ ឆ្នាំ២០១៤**

ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៥

| កាលបរិច្ឆេទ | ពេលវេលា | ចំនួនម៉ោង | ប្រធានបទ |
|---|---|---|---|
| ១០/០១/២០១៥ | ៨:០០-១០:០០ព្រឹក | ៣០នាទី | ពន្ធលើប្រាក់បៀវត្ស |
| | | ២៥នាទី | ពន្ធកាត់ទុកទូទៅ |
| | | ១៥នាទី | ពន្ធលើអចលនទ្រព្យ |
| | | ៣៥នាទី | អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករបំភ្លឺសាធារណៈ អាករលើការស្នាក់នៅ |
| | | ១៥នាទី | និងសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ។ |
| | ១០:០០-១០:១៥ព្រឹក | ១៥នាទី | សម្រាក |
| | ១០:១៥-១១:០០ព្រឹក | ៤៥នាទី | អាករលើតម្លៃបន្ថែម |
| | ១១:០០-១២:១៥ព្រឹក | ១ម៉:១៥នាទី | ពន្ធលើប្រាក់ចំណេញ |

រាជធានីភ្នំពេញ ថ្ងៃទី 29 ខែ 12 ឆ្នាំ២០១៥ 2014

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ

**គង់ វិបុល**